**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣៨ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការប្រែក្លាយសាលានាយទាហានចម្រុះ ទៅជា វិទ្យាស្ថានធំពហុជំនាញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០០៩

## សម្រេច

**មាត្រា ១.-**

ត្រូវបានប្រែក្លាយសាលានាយទាហានចម្រុះ ទៅជាវិទ្យាស្ថានទ័ពជើងគោក មានកម្រិតស្មើគ្រឹះស្ថានឧត្តមសិក្សា ។ វិទ្យាស្ថានទ័ពជើងគោក សរសេរអក្សរកាត់ថា វ.ឆ.ជ.គ. ។ វ.ឆ.ជ.គ. មានទីតាំងបច្ចុប្បន្ននៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ២.-**

វិទ្យាស្ថានទ័ពជើងគោក មានតួនាទីនិងភារកិច្ចបណ្តុះបណ្តាល នាយទាហានបរមទ័ពជើងគោក និងស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសយោធា ចំណេះដឹងទូទៅដល់កម្រិត បរិញ្ញាបត្ររង បរិញ្ញាបត្រ និងវិក្រឹតការ លើមុខជំនាញកងទ័ពជើងគោក ។ វ.ឆ.ជ.គ. ត្រូវរៀបចំកម្មវិធីសិក្សាគ្រប់កម្រិត និងគ្រប់មុខជំនាញតាមផែនការរបស់ក្រសួងការពារជាតិ ។

**មាត្រា ៣.-**

វិទ្យាស្ថានទ័ពជើងគោក ស្ថិតនៅក្រោមការគ្រប់គ្រង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ។ វិទ្យាស្ថានទ័ពជើងគោក ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤.-**

វិទ្យាស្ថានទ័ពជើងគោក មានថ្នាក់បណ្តុះបណ្តាល និង វគ្គវិក្រឹតការនាយទាហានបរមទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ តាមមុខជំនាញ ដូចខាងក្រោម ÷

- បញ្ជាការ ថ្មើរជើង
- បញ្ជាការ ស៊ើបការ
- បញ្ជាការ រថក្រោះ រថពាសដែក
- បញ្ជាការ កាំភ្លើងធំ
- បញ្ជាការ ការពារអាកាស
- បញ្ជាការ វិស្វកម្ម
- បញ្ជាការ បញ្ជូនសារ
- បញ្ជាការ គីមីសាស្ត្រ
- បញ្ជាការ ការពារព្រំដែន ។

ទៅអនាគត យោងតាមសេចក្តីត្រូវការចាំបាច់ក្នុងវិស័យការពារជាតិ វិទ្យាស្ថាននេះ អាចបន្ថែមមុខជំនាញដទៃទៀត ដោយអនុលោមតាមមាត្រា ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

លក្ខខណ្ឌជ្រើសរើស សិស្ស និស្សិត និងយោធិន ឱ្យចូលសិក្សានៅវិទ្យាស្ថានទ័ពជើងគោក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ឱ្យបានសមស្របទៅតាមបទដ្ឋាន ស្តីពីការកំណត់លក្ខខណ្ឌ នៃការចូលរៀននៅឧត្តមសិក្សា និងមធ្យមសិក្សាឯកទេស ។

www.pheakdeylaw.com

**មាត្រា ៦.-**

និស្សិតនាយទាហានបឋម ដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានទ័ពជើងគោក ហើយបានប្រឡងបញ្ចប់ការសិក្សាដោយជោគជ័យត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា ។

សញ្ញាបត្របញ្ចប់ការសិក្សា នៃវិទ្យាស្ថានទ័ពជើងគោក មានតម្លៃសមមូល បរិញ្ញាបត្ររង បរិញ្ញាបត្រ នៃកម្រិតបណ្តុះបណ្តាលនៅគ្រឹះស្ថានឧត្តមសិក្សា ។

សញ្ញាបត្រនេះ ត្រូវចុះហត្ថលេខាដោយនាយកវិទ្យាស្ថានទ័ពជើងគោក និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ៧.-**

ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវសហការក្នុងការរៀបចំកម្មវិធីសិក្សា និងជ្រើសរើសគ្រូឧត្តមសិក្សា និងសាស្ត្រាចារ្យ មកបង្រៀននៅវិទ្យាស្ថានទ័ពជើងគោកតាមតម្រូវការ និងភារកិច្ចបណ្តុះបណ្តាលធនធានមនុស្ស ក្នុងកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៨.-**

ការរៀបចំ និងការប្រព្រឹត្តទៅ នៃវិទ្យាស្ថានទ័ពជើងគោក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com